ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ...២៤៧០ ប្រ.ក

# ប្រកាស
## ស្តីពី
## ការលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៣០៦/១២២ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានឃើញអនុក្រឹត្យ លេខ១៦អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
-តាមសំណើលេខ ៣.២០០៧ ទ្រ.ជ.ក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ របស់លោក ប៉ែន សុវណ្ណ ប្រធានគណបក្សទ្រទ្រង់ជាតិកម្ពុជា អក្សរកាត់ "ទ្រ.ជ.ក"។

## សម្រេច

**ប្រការ១ :** លុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ **គណបក្សទ្រទ្រង់ជាតិកម្ពុជា** ដែលមានទីស្នាក់ការកណ្តាលតាំងនៅភូមិ ស្នោ ឃុំ រកាក្នុង ស្រុក ដូនកែវ ខេត្ត តាកែវ ។

**ប្រការ២ :** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល និង គណបក្សទ្រទ្រង់ជាតិកម្ពុជា ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី...១៦...ខែសីហា...ឆ្នាំ២០០៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល :**
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
"ដើម្បីជូនជ្រាប"
-គ្រប់សាលាខេត្ត-ក្រុង
-ដូចប្រការ២
"ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ